**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៥៤. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបំពេញបន្ថែមលើអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែមលើអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្មជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

# រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្មជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែមលើអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

**មាត្រា ១.-**

ត្រូវបានបំពេញបន្ថែមក្នុងមាត្រា១ នៃអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែមលើអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល នូវខ្លឹមសារមាត្រា១២ ត្រង់ចំណុច១២.៤ ដូចខាងក្រោមៈ

មាត្រា១២.

១២.៤.ថ្មី សាកលវិទ្យាល័យភូមិន្ទកសិកម្ម មានរចនាសម្ព័ន្ធដូចតទៅ :

ក.មហាវិទ្យាល័យ :

- មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម
- មហាវិទ្យាល័យវិទ្យាសាស្ត្រសត្វ
- មហាវិទ្យាល័យវេជ្ជសាស្ត្រសត្វ
- មហាវិទ្យាល័យវិទ្យាសាស្ត្រជលផល
- មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ
- មហាវិទ្យាល័យវិស្វកម្មកសិកម្ម
- មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ
- មហាវិទ្យាល័យកសិឧស្សាហកម្ម
- មហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី
- មហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ ។

ខ.សាលាក្រោយឧត្តម ។

គ.ផ្នែកសិក្សា ។

ឃ.ផ្នែកស្រាវជ្រាវនិងផ្សព្វផ្សាយ ។

ង.ផ្នែកថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ។

**មាត្រា ២.-**

ក្រៅពីនេះ ខ្លឹមសារអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែមលើអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល នៅរក្សាជាធរមានដដែល ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ